ប្រការ ៥ : សមាជិកគណៈកម្មាធិការនេះត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។ ក្នុងករណីដែលប្រធានអវត្តមាន អនុប្រធានដឹកនាំប្រជុំជំនួស ។

ប្រការ ៦ : គណៈកម្មាធិការដឹកនាំការងារនេះ ត្រូវប្រជុំរៀងរាល់បីខែម្តង ដើម្បីពិគ្រោះ និងពិភាក្សាលើរបៀបវារៈដែលរៀបចំឡើងដោយលេខាធិការដ្ឋានបច្ចេកទេស ។ ក្នុងករណីមានការងារចាំបាច់ ត្រូវប្រជុំវិសាមញ្ញ ។

ប្រការ ៧ : គណៈកម្មាធិការដឹកនាំការងារនេះ អាចអញ្ជើញមន្ត្រីជំនាញតាមស្ថាប័នពាក់ព័ន្ធ ឲ្យមកចូលរួមប្រជុំ និងពិគ្រោះការងារជំនាញតាមការចាំបាច់ ។

ប្រការ ៨ : គណៈកម្មាធិការដឹកនាំការងារនេះ មានសិទ្ធិប្រើត្រាក្រសួងផែនការ ។

ប្រការ ៩ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ រដ្ឋមន្ត្រីឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ទេសាភិបាលធនាគារជាតិនៃកម្ពុជា ឯកឧត្តម លោក លោកស្រី ដូចមានក្នុងប្រការ ២ មានភារកិច្ចរៀងខ្លួនអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

រាជធានីភ្នំពេញ, ថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០០

## សេចក្តីសំរេចលេខ ៣៣ សសរ
## ស្តីពីការផ្ទេរសិទ្ធិ នៃរាជរដ្ឋាភិបាលកម្ពុជា

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

### សំរេច

**ប្រការ ១ :** ត្រូវបានផ្ទេរសិទ្ធិជូនឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី និងជាសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជា នាយករដ្ឋមន្ត្រីស្តីទី នៃរាជរដ្ឋាភិបាលកម្ពុជា ជំនួសសម្តេចនាយករដ្ឋមន្ត្រី ដែលត្រូវអញ្ជើញទៅចូលរួមប្រជុំក្រុមពិគ្រោះយោបល់ជាមួយបណ្តាប្រទេស អង្គការនានា និងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ដែលបានផ្តល់ជំនួយ នៅទីក្រុងប៉ារីស នៃសាធារណរដ្ឋបារាំង ចាប់ពីថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០០០ រហូតដល់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា អញ្ជើញវិលត្រឡប់មកកាន់មាតុប្រទេសវិញ ។

**ប្រការ ២ :** រដ្ឋមន្ត្រីទទួលបន្ទុកស្តីទីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នប្រតិភូរាជរដ្ឋាភិបាល អភិបាលគ្រប់ខេត្ត ក្រុង និង ឯកឧត្តម ស ខេង ត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

រាជធានីភ្នំពេញ, ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០០០

## សេចក្តីសំរេចលេខ ៣៤ សសរ
## ស្តីពីការផ្ទេរសិទ្ធិ នៃរាជរដ្ឋាភិបាលកម្ពុជា

***

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

### សំរេច

**ប្រការ ១ :** ត្រូវបានផ្ទេរសិទ្ធិជូនឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី និងជាសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជា នាយករដ្ឋមន្ត្រីស្តីទី នៃរាជរដ្ឋាភិបាលកម្ពុជា ជំនួសសម្តេចនាយករដ្ឋមន្ត្រី ដែលត្រូវអញ្ជើញទៅបំពេញបេសកកម្មផ្លូវការ នៅសាធារណរដ្ឋសិង្ហបុរី ចាប់ពីថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០០០ រហូតដល់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា អញ្ជើញវិលត្រឡប់មកកាន់មាតុប្រទេសវិញ ។